**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ០០៣ សហវ

ថ្ងៃព្រហស្បតិ៍ ៧កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨

# សារាចរណែនាំ
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដំណាក់កាលទី១

អនុវត្តតាមកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងយុទ្ធសាស្រ្តកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ ដើម្បីគ្រប់គ្រងចំណូលមិនមែនសារពើពន្ធប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបង្កើតប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (Non-Tax Revenue Management Information System - NRMIS) ដោយមានការចូលរួមពីក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ។

ក្នុងដំណាក់កាលទី១ ប្រព័ន្ធ NRMIS នឹងដាក់ឱ្យអនុវត្តចាប់ពីខែមករា ឆ្នាំ ២០១៨ តទៅ សម្រាប់ក្រសួង ស្ថាប័នចំនួន១៤ រួមមាន÷ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល, ក្រសួងមហាផ្ទៃ, ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងសុខាភិបាល, ក្រសួងរ៉ែនិងថាមពល, ក្រសួងពាណិជ្ជកម្ម, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ, ក្រសួងសាធារណការនិងដឹកជញ្ជូន, ក្រសួងទេសចរណ៍, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ, និងក្រសួងឧស្សាហកម្មនិងសិប្បកម្ម។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងបន្តរៀបចំលេខកូដចំណូលមិនមែនសារពើពន្ធជាមួយក្រសួង ស្ថាប័នផ្សេងទៀត មន្ទីរជំនាញរាជធានី ខេត្ត រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពប្រមូលចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត នៅក្នុងដំណាក់កាលទី២ និងបន្តបន្ទាប់។

ក្រសួង ស្ថាប័នទាំង ១៤ ខាងលើ ត្រូវប្រើប្រាស់លេខកូដចំណូលមិនមែនសារពើពន្ធ ដោយលម្អិតតាមចំណូលពីសេវាសាធារណៈ និងចំណូលពីទ្រព្យសម្បត្តិរដ្ឋ ស្របតាមលេខកូដដែលបានកំណត់។ គ្រប់ចំណូលមិនមែនសារពើពន្ធទាំងអស់ដែលអាចប្រមូលនិងបង់ចូលថវិការដ្ឋបាន លុះត្រាណាតែមានលេខកូដចំណូលដែលកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានរតនាគារជាតិ ឬអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ) តាមការស្នើសុំរបស់ក្រសួង ស្ថាប័នសាមី។ បញ្ជីលេខកូដចំណូលមិនមែនសារពើពន្ធនៃក្រសួង ស្ថាប័ននីមួយៗ ជាឧបសម្ព័ន្ធនៃសារាចរណែនាំនេះ។

ដើម្បីមានមូលដ្ឋានក្នុងការប្រើប្រាស់លេខកូដចំណូលមិនមែនសារពើពន្ធពីចំណូលសេវាសាធារណៈ និងចំណូលពីទ្រព្យសម្បត្តិរដ្ឋសម្រាប់ក្រសួង ស្ថាប័នចំនួន១៤ នៅរដ្ឋបាលថ្នាក់ជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចេញសារាចរណែនាំអនុវត្តដែលមានខ្លឹមសារដូចខាងក្រោម÷

❖ **នីតិវិធីនៃការប្រមូលនិងកត់ត្រាចំណូលទៅក្នុងប្រព័ន្ធ NRMIS និងបង់ចំណូលទៅធនាគារជាតិនៃកម្ពុជា ធនាគារដៃគូ ឬ/និងគ្រឹះស្ថានហិរញ្ញវត្ថុ ដៃគូ ÷**

១. ការកត់ត្រាចំណូលទៅក្នុងប្រព័ន្ធNRMIS÷ ក្រសួង ស្ថាប័ន ក្រោយពីទទួលបានចំណូលពីសេវាសាធារណៈ ឬចំណូលពីទ្រព្យសម្បត្តិរដ្ឋ ត្រូវកត់ត្រាចំណូលទៅក្នុងប្រព័ន្ធ NRMIS។

២. ពេលបង់ចំណូលទៅធនាគារជាតិ នៃកម្ពុជា, ធនាគារដៃគូ ឬ/និងគ្រឹះស្ថានហិរញ្ញវត្ថុដៃគូ÷

- ចំពោះចំណូលពីទ្រព្យសម្បត្តិរដ្ឋ ក្រសួង ស្ថាប័ន ត្រូវបោះពុម្ពវិក្កយបត្រចេញពីប្រព័ន្ធ NRMIS ជូនអតិថិជន ដើម្បីបង់ប្រាក់នៅធនាគារជាតិនៃកម្ពុជា, ធនាគារដៃគូ ឬ/និងគ្រឹះស្ថានហិរញ្ញវត្ថុដៃគូ
- ចំពោះចំណូលពីសេវាសាធារណៈ ក្រសួង ស្ថាប័ន ត្រូវបោះពុម្ពវិក្កយបត្រចេញពីប្រព័ន្ធ NRMIS ចំនួន០២ច្បាប់ ដោយ ០១ច្បាប់រក្សាទុកជូនធនាគារជាតិនៃកម្ពុជា, ធនាគារដៃគូ ឬ/និងគ្រឹះស្ថានហិរញ្ញវត្ថុដៃគូនិង ០១ច្បាប់ទៀត រក្សាទុកដោយរដ្ឋទេយ្យករចំណូល ឬគណនេយ្យកររបស់ក្រសួង ស្ថាប័នសាមី ដើម្បីភ្ជាប់ជាមួយសាច់ប្រាក់ដែលត្រូវបង់ ឬបង្វែរ (គណនីចរន្តរបស់ក្រសួង ស្ថាប័ន) ចូលគណនីទោលរតនាគារ (TSA) នៅធនាគារជាតិ នៃកម្ពុជា
- ក្រោយពីបានបង់ប្រាក់ចូលTSA ក្រសួង ស្ថាប័ន ត្រូវកត់ត្រាលេខយោងលើបណ្ណបង់ប្រាក់ ឬប្រកាសឥណពន្ធ ចូលក្នុងប្រព័ន្ធ NRMIS ដើម្បីបញ្ចប់ប្រតិបត្តិការនៃការបោះពុម្ពវិក្កយបត្រ (ក្នុងករណីជាប្រាក់ដុល្លារ ត្រូវបញ្ចូលអត្រាប្តូរប្រាក់ដែលបានកំណត់ដោយធនាគារជាតិ នៃកម្ពុជា)។

៣. ការបង្វែរចំណូលទៅថវិកាជាតិ÷

- ក្រសួង ស្ថាប័ន ជ្រើសរើសយកប្រតិបត្តិការដែលបានបង់ចូល TSA ដើម្បីបោះពុម្ពសលាកបត្របង់ចំណូលថវិកាចេញពីប្រព័ន្ធ NRMIS
- រដ្ឋទេយ្យករចំណូល ឬគណនេយ្យករចំណូលត្រូវពិនិត្យ និងចុះហត្ថលេខាលើសលាកបត្ររួចបញ្ជូនមកអគ្គនាយកដ្ឋានរតនាគារជាតិជាមុន តាមរយៈប្រព័ន្ធទំនាក់ទំនងសង្គមTelegram របស់ក្រសួង ស្ថាប័ននីមួយៗដែលបានបង្កើតរួចជាស្រេចនាពេលកន្លងមក។ រីឯ ឯកសារច្បាប់ដើមត្រូវដាក់ជូនថ្នាក់ដឹកនាំរបស់ក្រសួង ស្ថាប័នសាមីចុះហត្ថលេខារួចបញ្ជូនមកអគ្គនាយកដ្ឋានរតនាគារជាតិតាមក្រោយ។

៤. ការទូទាត់ប្រាក់រង្វាន់÷ ដើម្បីរៀបចំការទូទាត់ប្រាក់រង្វាន់ដែលក្រសួង ស្ថាប័ន បានបុរេប្រទានពីថវិកាជាតិកន្លងមក ក្រសួង ស្ថាប័ន ត្រូវប្រើប្រាស់ប្រព័ន្ធNRMIS ដោយត្រូវជ្រើសរើសយកសលាកបត្រចំណូលថវិកាជាតិដែលបានបង់ចូលថវិកាជាតិរួច (សលាកបត្របានបង្កើតឡើង ដើម្បីបង្វែរចំណូលដែលបានបង់ចូលគណនីទោលរតនាគារ TSA ចូលថវិកាជាតិ) បន្ទាប់មកត្រូវបោះពុម្ពលិខិតស្នើសុំផ្សេងៗ និង

របាយការណ៍ស្ដីពីការអនុវត្តចំណូល, តារាងសម្រង់សលាកបត្រចំណូលថវិកាជាតិ និងប័ណ្ណបង់ប្រាក់ តារាងគណនាប្រាក់រង្វាន់ និងរបាយការណ៍ស្ដីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្ដល់កន្លងមក។

បន្ទាប់ពីទទួលបានសារាចរណែនាំនេះ ក្រសួង ស្ថាប័ន ត្រូវរៀបចំសេចក្ដីជូនដំណឹងជាលាយលក្ខណ៍អក្សរបន្ថែមទៀតទៅអ្នកជាប់កាតព្វកិច្ចបង់ចំណូល និងធនាគារដៃគូ ឬ/ និងគ្រឹះស្ថានហិរញ្ញវត្ថុដៃគូរបស់ក្រសួង ស្ថាប័នសាមីឱ្យប្រើប្រាស់លេខកូដសម្រាប់ការបង់ចំណូលជាកំហិត។

ក្រសួង ស្ថាប័ន នៃរដ្ឋបាលថ្នាក់ជាតិទាំង ១៤ ត្រូវអនុវត្តសារាចរណែនាំនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន:-**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- គ្រប់ក្រសួង ស្ថាប័ន នៃរដ្ឋបាលថ្នាក់ជាតិទាំង ១៤
- អគ្គនាយកដ្ឋានពាក់ព័ន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ